ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ :

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែ ឆ្នាំ ២០១០

# ប្រកាស
## ស្តីពី
## ចំណាត់ក្រុមនីតិវិធីសំរាប់ការចុះត្រួតពិនិត្យរោងចក្រ-សិប្បកម្ម

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១** **គោលបំណង**

-ប្រកាសនេះមានគោលបំណង:

- បង្កើតនូវក្របខ័ណ្ឌឯកភាពមួយសំរាប់ពង្រឹងការអនុវត្តច្បាប់ ដើម្បីធានាគុណភាព សុវត្ថិភាព ផលិតផល និងដំណើរការផលិតកម្មរបស់រោងចក្រ-សិប្បកម្ម ដែលស្ថិតនៅក្រោមច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។
- ផ្តល់នូវគោលការណ៍រួម និងនីតិវិធីច្បាស់លាស់សំរាប់មន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការអនុវត្ត និងដំណើរការការងារអធិការកិច្ចនៅរោងចក្រ-សិប្បកម្ម ស្របតាមច្បាប់ជាធរមាន ក្នុងគោលបំណងគ្រប់គ្រងការអនុញ្ញាតឱ្យបង្កើត និងដំណើរការរោងចក្រ-សិប្បកម្ម
- ផ្សព្វផ្សាយជាសាធារណៈដល់រោងចក្រ-សិប្បកម្មទាំងអស់ និង



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

នីតិវិធីអធិការកិច្ចដែលត្រូវអនុវត្ត ចំពោះរោងចក្រ-សិប្បកម្ម ដែលស្ថិតនៅក្រោមច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ដែលពាក់ព័ន្ធនឹងការអនុញ្ញាតឱ្យបង្កើត និងដំណើរការរោងចក្រ-សិប្បកម្ម ។

## ប្រការ២ និយមន័យ

-**ហានិភ័យ:** សំដៅលើស្ថានភាព ឬ ការអនុវត្តដែលធ្វើឱ្យដំណើរការប្រព្រឹត្តិទៅរបស់រោងចក្រ-សិប្បកម្ម ឬ ផលិតផលដែលផលិតដោយរោងចក្រ-សិប្បកម្ម គ្មានសុវត្ថិភាព បង្កឱ្យមានគ្រោះថ្នាក់ ប៉ះពាល់ដល់សុខភាព ឬ បង្កការគំរាមកំហែងដល់សុខភាព សុវត្ថិភាពរបស់អ្នកប្រើប្រាស់ និងសង្គម ។

-**ភាពមិនអនុលោម:** សំដៅលើស្ថានភាព ឬ ការអនុវត្តដែលមិនស្របតាមបទដ្ឋានបច្ចេកទេសស្តង់ដារបញ្ជា ឬ បទប្បញ្ញត្តិកំណត់ដោយរាជរដ្ឋាភិបាលស្របតាមច្បាប់ ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា និងច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

- **ផលិតផលមានគុណភាព និងសុវត្ថិភាព:** សំដៅលើផលិតផលដែល
    - មានភាពសមស្របសំរាប់ការប្រើប្រាស់ ដោយត្រូវបានផលិតតាមបទដ្ឋានបច្ចេកទេស និងវិធានអនាម័យត្រឹមត្រូវ ស្របតាមគោលបំណងប្រើប្រាស់របស់ផលិតផលនោះ ។
    - មានសុវត្ថិភាពដល់អ្នកប្រើប្រាស់ ដោយត្រូវបានផលិតតាមគោលការណ៍ និងវិធានផ្សេងៗ ស្តីពី សុវត្ថិភាព សមស្របតាមគោលបំណងនៃការប្រើប្រាស់ផលិតផល និងដោយពុំមានផ្ទុកសារធាតុពុល ឬ មានហានិភ័យ លើសពីកំរិតអនុញ្ញាតក្នុងការការពារសុខភាពរបស់អ្នកប្រើប្រាស់ ។

- **កំរិតហានិភ័យខ្ពស់:** សំដៅលើភាពមិនអនុលោម ដែលបង្កឱ្យមានហានិភ័យ ឬ គ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ និង/ឬ បង្កការគំរាមកំហែងធ្ងន់ធ្ងរដល់សុខភាព និងសុវត្ថិភាពសាធារណៈ ។

- **កំរិតហានិភ័យមធ្យម:** សំដៅលើភាពមិនអនុលោម ដែលបង្កឱ្យមានហានិភ័យ ឬ គ្រោះថ្នាក់តិចតួចដល់សុខភាពសាធារណៈ និង/ឬ បង្កការគំរាមកំហែងដល់សុខភាព និងសុវត្ថិភាពសាធារណៈដោយពុំត្រូវបានចាត់ទុកថាមានកំរិតធ្ងន់ធ្ងរ ។

- **កំរិតហានិភ័យទាប:** សំដៅលើភាពមិនអនុលោម ដែលពុំបង្កឱ្យមានហានិភ័យ ឬគ្រោះថ្នាក់ដល់សុខភាពសាធារណៈ និង/ឬ ពុំបង្កឱ្យការគំរាមកំហែងដល់សុខភាព និងសុវត្ថិភាពសាធារណៈ ។

## <u>ប្រការ៣</u> ការធ្វើចំណាត់ថ្នាក់រោងចក្រ-សិប្បកម្មតាមកំរិតហានិភ័យ

-ក្នុងគោលបំណងជំរុញប្រសិទ្ធភាព និងគុណភាពនៃការងារត្រួតពិនិត្យអធិការកិច្ចបណ្តារោងចក្រ-សិប្បកម្មទាំងអស់ និងត្រូវរៀបចំធ្វើចំណាត់ថ្នាក់តាមកំរិតហានិភ័យ ផ្អែកលើកត្តាដូចខាងក្រោម:

១- ប្រភេទខ្សែសង្វាក់ផលិតកម្ម-កែច្នៃ និងគោលដៅប្រើប្រាស់ផលិតផល ។

២- ប្រវត្តិនៃភាពសុចរិត ការទទួលខុសត្រូវសង្គម និងភាពអនុលោមតាមលិខិតបទដ្ឋានរយៈពេលកន្លងមក ។

៣- លទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តន៍វិធានអនាម័យ កម្មវិធីគ្រប់គ្រងសុវត្ថិភាពឧស្សាហកម្ម និងគុណភាពផលិតផល ។

៤- ចំណេះដឹងរបស់កម្មករ និងអ្នកគ្រប់គ្រង ស្តីពី វិធានអនាម័យ សុវត្ថិភាព និងប្រព័ន្ធគ្រប់គ្រងគុណភាព ។

៥- ទំហំរោងចក្រ-សិប្បកម្ម ។

៦- ទំហំទីផ្សារផលិតផល ។

-ការរៀបចំធ្វើចំណាត់ថ្នាក់រោងចក្រ-សិប្បកម្ម ត្រូវអនុវត្តតាមគោលការណ៍ណែនាំ កំណត់ក្នុងសេចក្តីណែនាំដោយឡែក ដែលនឹងត្រូវធ្វើការចេញផ្សព្វផ្សាយ និងធ្វើបច្ចុប្បន្នភាពជាប្រចាំដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្របតាមបច្ចុប្បន្នភាពនៃសង្គម និងការរីកចំរើននៃវិទ្យាសាស្ត្របច្ចេកទេស ។

## <u>ប្រការ៤</u> ការចុះអធិការកិច្ចនៅរោងចក្រ-សិប្បកម្ម ដោយមន្ត្រីមានសមត្ថកិច្ច

-ការចុះធ្វើអធិការកិច្ចនៅតាមរោងចក្រ-សិប្បកម្មស្របតាមច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ត្រូវអនុវត្តដោយមន្ត្រីមានសមត្ថកិច្ច ដែលទទួលបានការតែងតាំងត្រឹមត្រូវដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

-មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសិទ្ធិ [illegible] ក្នុង [illegible] ក្រ និងសិប្បកម្ម គ្រប់ម៉ោងធ្វើការរបស់រោងចក្រតាមកាលកំណត់ [illegible] ណាត់ ដើម្បីត្រួតពិនិត្យគុណភាពស្ថានភាពរោងចក្រ-សិប្បកម្ម ម៉ាស៊ីន [illegible] ឬ

សកម្មភាពផ្សេងៗដែលរំលោភ ទៅលើបទប្បញ្ញត្តិនៃច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ សិទ្ធិ និងការទទួលខុសត្រូវរបស់មន្ត្រីមានសមត្ថកិច្ចត្រូវកំណត់ដូចចែងក្នុងប្រការ ៧ និង ៨ នៃប្រកាស នេះ ។

-មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នឹងចុះធ្វើអធិការកិច្ចរោងចក្រ-សិប្បកម្មយ៉ាងតិច ១ដង ក្នុងរយៈពេល ៣ឆ្នាំ ។ ការចុះធ្វើអធិការកិច្ចរោងចក្រ-សិប្បកម្មត្រូវកំណត់តាមចំណាត់ថ្នាក់តាមកំរិតថ្នាក់ហានិភ័យរបស់រោងចក្រ-សិប្បកម្មដូចតទៅ ៖

| កំរិតហានិភ័យរបស់រោងចក្រ-សិប្បកម្ម | កាលកំណត់នៃការធ្វើអធិការកិច្ច |
|---|---|
| ទាប | ១ដង/៣ឆ្នាំ |
| មធ្យម | ១ដង/១ឆ្នាំ |
| ខ្ពស់ | ២ដង/១ឆ្នាំ |

-ការធ្វើអធិការកិច្ចខាងលើមិនរាប់បញ្ចូល ការធ្វើអធិការកិច្ចដែលត្រូវធ្វើឡើងដើម្បីឆ្លើយតបទៅនឹងការតវ៉ារបស់អតិថិជន ឬ នៅពេលមានការកើតមានឡើងជាយថាហេតុនូវគ្រោះថ្នាក់ហានិភ័យ ឬការរាលដាលនៃជំងឺ ដែលបណ្តាលមកពីផលិតកម្ម ឬ ផលិតផលរបស់រោងចក្រ-សិប្បកម្ម ។

**ប្រការ៥ ការធ្វើបច្ចុប្បន្នភាពនៃចំណាត់ថ្នាក់រោងចក្រ-សិប្បកម្ម និងការយកសំណាកគំរូ**

-ចំណាត់ថ្នាក់រោងចក្រ-សិប្បកម្មនីមួយៗ ត្រូវពិនិត្យវាយតម្លៃឡើងវិញជាប្រចាំក្រោយការធ្វើអធិការកិច្ចម្តងៗ ។ ក្នុងគោលបំណង បញ្ជាក់ភាពត្រឹមត្រូវនៃព័ត៌មាន ភស្តុតាង ឬអំណះអំណាងផ្សេងៗ មន្ត្រីមានសមត្ថកិច្ច អាចកំណត់ធ្វើការយកសំណាក គំរូចាំបាច់ផ្សេងៗដើម្បីធ្វើការវិភាគនៅមន្ទីរពិសោធន៍ដោយម្ចាស់រោងចក្រ-សិប្បកម្ម ត្រូវទទួលបន្ទុកលើចំណាយថ្លៃវិភាគនានានៅមន្ទីរពិសោធន៍ ។ ការយកសំណាកគំរូវិភាគត្រូវធ្វើក្នុងបរិមាណសមស្របស្របតាមនីតិវិធី និងបទដ្ឋានបច្ចេកទេសដែលអនុវត្តសំរាប់គោលដៅត្រូវវិភាគ និងតាមកំរិតនៃហានិភ័យដែលអាចបង្កឡើង ។

**ប្រការ៦ គោលការណ៍សំខាន់ៗ និងលក្ខណៈសម្បត្តិរបស់មន្ត្រីមានសមត្ថកិច្ចដែលចុះធ្វើអធិការកិច្ចរោងចក្រ-សិប្បកម្ម**

-មន្ត្រីមានសមត្ថកិច្ចចុះធ្វើអធិការកិច្ចរោងចក្រ-សិប្បកម្ម ត្រូវគោរព និងអនុវត្តគោលការណ៍ដូចខាងក្រោម:

- មានសុវត្ថិភាពដល់អ្នកប្រើប្រាស់ ដោយត្រូវបានផលិតតាមគោលការណ៍ និង

វិធានផ្សេងៗស្តីពី សុវត្ថិភាពសមស្របតាមគោលបំណងនៃការប្រើប្រាស់ផលិតផលនោះ និងដោយពុំមានផ្ទុកសារធាតុពុល ឬ មានហានិភ័យលើសពីកំរិតអនុញ្ញាតក្នុងការការពារសុខភាពរបស់អ្នកប្រើប្រាស់ ។

- ផ្តល់អាទិភាពលើជីវិត និងសុខភាពសាធារណៈ អភិវឌ្ឍន៍សង្គម បរិស្ថាន និងភាពលូតលាស់របស់ធុរកិច្ច ។
- គោរពសិទ្ធិស្មើភាព និងផលប្រយោជន៍ស្របច្បាប់របស់ធុរជនទាំងអស់ ។
- ធានាភាពអព្យាក្រឹតក្នុងការធ្វើអធិការកិច្ច និង មិនលំអៀង ។
- មានតម្លាភាព លើការរៀបចំ និងអនុវត្តន៍ផែនការ និងការត្រួតពិនិត្យ ។
- មិនជ្រៀតជ្រែកនៅក្នុងសកម្មភាពធុរកិច្ចរបស់រោងចក្រ-សិប្បកម្ម ។

-មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលត្រូវមានការយល់ដឹងច្បាស់លាស់អំពីច្បាប់ លិខិតបទដ្ឋាន បច្ចេកទេស វិធានការនៃក្បួនអនុវត្តកម្មន្តសាលល្អ ប្រព័ន្ធគ្រប់គ្រងគុណភាព និងសុវត្ថិភាព និងគោលការណ៍អនាម័យនានាក្នុងមូលដ្ឋានឧស្សាហកម្មកម្មន្តសាល ព្រមទាំងបច្ចេកទេសអធិការកិច្ច វិធីសាស្ត្រយកសំណាកគំរូសំរាប់វិភាគគុណភាព និងបានឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវអំពីការងារអធិការកិច្ច ។

-មន្ត្រីមានសមត្ថកិច្ច ត្រូវបន្តការសិក្សាស្រាវជ្រាវជាប្រចាំដើម្បីលើកកំពស់សមត្ថភាព និងចំណេះដឹងរបស់ខ្លួនសមស្របតាមបច្ចុប្បន្នភាពនៃការអភិវឌ្ឍន៍ នៅក្នុងវិស័យឧស្សាហកម្ម ។

## ប្រការ៧ សិទ្ធិ និងការទទួលខុសត្រូវរបស់មន្ត្រីមានសមត្ថកិច្ច

-មន្ត្រីមានសមត្ថកិច្ច និងជំនួយរបស់ខ្លួន(បើមាន) ត្រូវមានការអនុញ្ញាតពីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងករណីក្រសួងបានប្រតិភូកម្មអំណាចឱ្យមុននឹងចុះពិនិត្យ និងដំណើរការអធិការកិច្ចនៅរោងចក្រ-សិប្បកម្ម ។ មន្ត្រីមានសមត្ថកិច្ច ត្រូវមាន និងបង្ហាញលិខិតបញ្ជាបេសកកម្មពីអង្គភាពរបស់ខ្លួន និងប័ណ្ណសំគាល់ខ្លួនដល់ម្ចាស់រោងចក្រ-សិប្បកម្ម នៅមុនពេលចាប់ផ្តើម ដំណើរការអធិការកិច្ច ។

-ដោយមានការអនុញ្ញាតជាមុនពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មន្ត្រីមានសមត្ថកិច្ចមានសិទ្ធិចុះធ្វើអធិការកិច្ចដោយមានការជូនដំណឹងជាមុន ឬ ដោយពុំមានការជូនដំណឹងជាមុនដល់ម្ចាស់រោងចក្រ-សិប្បកម្ម ។ ក្នុងករណីមានការជូនដំណឹង ជាមុនសេចក្តីជូនដំណឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងទុកពេលវេលាសមស្របសំរាប់រោងចក្រ-សិប្បកម្មត្រៀមទទួលជួប ។ ការចុះធ្វើអធិការកិច្ចដោយពុំមានការជូនដំណឹងជាមុនត្រូវអនុវត្តតែក្នុងករណីចាំបាច់ក្នុងការ ត្រួតពិនិត្យផ្ទៀងផ្ទាត់អំណះអំណាងពីការអនុវត្ត[illegible]របស់

ម្ចាស់រោងចក្រ-សិប្បកម្ម ឬ សកម្មភាពរំលោភទៅលើបទប្បញ្ញត្តិនៃច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

-ក្នុងពេលបំពេញភារកិច្ចការងារអធិការកិច្ចរោងចក្រ-សិប្បកម្ម មន្ត្រីមានសមត្ថកិច្ចមានសិទ្ធិ:

- មិនជ្រៀតជ្រែកនៅក្នុងសកម្មភាពធុរកិច្ចរបស់រោងចក្រ-សិប្បកម្ម ។
- បញ្ឈប់សកម្មភាពណាមួយ ដែលរារាំងដល់ដំណើរការអធិការកិច្ច ។
- ធ្វើការយកសំណាកគំរូ ឬ ផលិតផលក្នុងបរិមាណសមស្រប ដើម្បីមកវិភាគគុណភាព រួមជាមួយនឹងឯកសារពាក់ព័ន្ធផ្សេងៗ ។
- ធ្វើការស្រាវជ្រាវ បញ្ឈប់ ឬ ឃាត់ទុកនូវផលិតផល សម្ភារៈ វត្ថុធាតុដើម និងឯកសារពាក់ព័ន្ធនានាដែលអាចបណ្តាលឱ្យមានអន្តរាយដល់មនុស្ស ឬ ដល់ទ្រព្យសម្បត្តិក្នុង ឬ នៅជិតខាងរោងចក្រ-សិប្បកម្ម ។
- សាកសួរ ឬ កោះអញ្ជើញម្ចាស់រោងចក្រ-សិប្បកម្ម អ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម និយោជិត ឬ កម្មកររោងចក្រ-សិប្បកម្ម មកបំភ្លឺព័ត៌មាន ឬ សុំឱ្យ ផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធ ។

-មន្ត្រីមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវលើការបង្កឱ្យមានការខូចខាតដល់ធុរកិច្ចរបស់ម្ចាស់ រោងចក្រ-សិប្បកម្ម ដែលបណ្តាលមកពីសកម្មភាពណាមួយមិនអនុលោមតាមច្បាប់របស់ខ្លួន និងការធានាមិនបញ្ចេញព័ត៌មានសំងាត់របស់ធុរកិច្ចដែលទទួលបានមកពីការធ្វើ អធិការកិច្ចនេះ ។

-មន្ត្រីមានសមត្ថកិច្ច ត្រូវផ្តល់របាយការណ៍អធិការកិច្ចដល់ម្ចាស់រោងចក្រ-សិប្បកម្ម ឬ តំណាងក្នុងរយៈពេលយ៉ាងយូរ ០៧ថ្ងៃ នៃថ្ងៃធ្វើការក្រោយបានបញ្ចប់ការងារអធិការកិច្ច និងត្រូវផ្តល់ប្រឹក្សាយោបល់ផ្សេងៗ ជាមួយម្ចាស់រោងចក្រ-សិប្បកម្ម ពាក់ព័ន្ធនឹងបញ្ហានានាក្នុងការធ្វើអធិការកិច្ច ។ របាយការណ៍អធិការកិច្ច ត្រូវកត់ត្រារាល់ការឆ្លើយតបទំនាក់ទំនងនឹងអំណះអំណាងផ្សេងៗរបស់ម្ចាស់រោងចក្រ-សិប្បកម្ម ក្នុងពេលធ្វើអធិការកិច្ច ។

**<u>ប្រការ៨</u> សិទ្ធិ ភារកិច្ច និង ការទទួលខុសត្រូវរបស់ម្ចាស់រោងចក្រ-សិប្បកម្ម**

-ពេលចុះធ្វើអធិការកិច្ចរបស់មន្ត្រីមានសមត្ថកិច្ច ម្ចាស់ ឬ តំណាងរោងចក្រ-សិប្បកម្មមានសិទ្ធិ:

- សួររកឯកសារ និងទាមទារឱ្យផ្តល់ព័ត៌មានអំពីបទប្បញ្ញត្តិ និងលិខិតតែងតាំងដែលផ្តល់សិទ្ធិដល់មន្ត្រីមានសមត្ថកិច្ចក្នុងការចុះធ្វើអធិការកិច្ចនៅរោងចក្រ-សិប្បកម្មរបស់ខ្លួន ។
- ធ្វើការឆ្លើយបំភ្លឺ និងផ្តល់អំណះអំណាងផ្សេងៗ ក្នុងគោលបំណងធ្វើការបញ្ជាក់ និងការពារនីតិវិធីនៃការអនុវត្តនៅក្នុងរោងចក្រ-សិប្បកម្មរបស់ខ្លួន

និងទាមទារឱ្យមន្ត្រីមានសមត្ថកិច្ចកត់ត្រារាល់ការឆ្លើយតប ឬ មតិយោបល់ទាំងនេះក្នុងកំណត់ហេតុ និងរបាយការណ៍លទ្ធផលអធិការកិច្ច ។

- រារាំង មិនអនុញ្ញាតឱ្យមន្ត្រីមានសមត្ថកិច្ចចូលត្រួតពិនិត្យនៅក្នុងរោងចក្រ-សិប្បកម្មរបស់ខ្លួនដោយពុំមាន ឬ មិនបានផ្តល់លិខិតតែងតាំង និងលិខិតបេសកកម្មដែលផ្តល់សិទ្ធិក្នុងការចុះធ្វើអធិការកិច្ច ។
- មានវត្តមានជាមួយមន្ត្រីមានសមត្ថកិច្ចនៅពេលធ្វើអធិការកិច្ច ។
- ទាមទារមិនឱ្យបញ្ចេញផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានដែលជាការសំងាត់ពាណិជ្ជកម្ម ។
- ទទួលបាននូវរបាយការណ៍លទ្ធផលនៃការចុះធ្វើអធិការកិច្ច ។
- ដាក់នូវការពន្យល់ជាលាយលក្ខណ៍អក្សរចំពោះការប្រឆាំងលទ្ធផល ឬ សកម្មភាពមិនប្រក្រតីនៃការធ្វើអធិការកិច្ច។
- ធ្វើការជំទាស់ តវ៉ា ចំពោះសកម្មភាពមិនស្របច្បាប់ដែលធ្វើឡើងដោយមន្ត្រីមានសមត្ថកិច្ច ។

-ពេលចុះធ្វើអធិការកិច្ចរបស់មន្ត្រីមានសមត្ថកិច្ច ម្ចាស់ ឬ តំណាងរោងចក្រ-សិប្បកម្ម មានកាតព្វកិច្ច និងការទទួលខុសត្រូវដូចតទៅៈ

- អនុញ្ញាតឱ្យមន្ត្រីមានសមត្ថកិច្ច ចូលពិនិត្យរោងចក្រ-សិប្បកម្ម និងផ្តល់ការសហការក្នុងការធ្វើអធិការកិច្ច និងត្រួតពិនិត្យនៅក្នុងរោងចក្រ-សិប្បកម្ម ដូចមានចែងនៅក្នុងច្បាប់ ។
- ធ្វើការកែតម្រូវចំពោះភាពមិនអនុលោមផ្សេងៗស្របតាមច្បាប់ ។
- ផ្តល់នូវឯកសារសំណាកគំរូ និងទូទាត់ចំណាយលើការវិភាគផ្សេងៗលើសំណាកគំរូ។
- ធ្វើការបំភ្លឺ ឬ ពន្យល់ផ្សេងៗ និងចូលរួមប្រជុំលើបញ្ហាពាក់ព័ន្ធនានាក្នុងពេលធ្វើអធិការកិច្ច ។
- ប្រកាន់ខ្ជាប់នូវសុចរិតភាព ភាពស្មោះត្រង់ និងការទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធផ្សេងៗ ។
- អនុវត្តការងារអធិការកិច្ចរោងចក្រ-សិប្បកម្មដោយខ្លួនឯង ដើម្បីបំពេញឆ្លើយតប នឹងបញ្ជីសំនួរអធិការកិច្ចដែលកំណត់ផ្តល់ឱ្យដោយក្រសួង និងផ្តល់លទ្ធផលនៃការងារស្វ័យអធិការកិច្ចនេះជូនមកក្រសួងពិនិត្យ និងសំរេច ។

**<u>ប្រការ៩</u> របៀបដំណើរការការងារអធិការកិច្ចរោងចក្រ-សិប្បកម្ម ដោយមន្ត្រីមានសមត្ថកិច្ច**

-មន្ត្រីមានសមត្ថកិច្ចត្រូវជូនដំណឹងជាមុនយ៉ាងតិចចំនួន ១០ថ្ងៃ ដល់ម្ចាស់រោងចក្រ-សិប្បកម្ម អំពីការចុះធ្វើអធិការកិច្ចតាមកាលកំណត់ ដើម្បីឱ្យម្ចាស់រោងចក្រ-សិប្បកម្មរៀបចំ ... ចាំជួប

និងធ្វើការជាមួយក្នុងពេលធ្វើអធិការកិច្ច និងរៀបចំឯកសារព័ត៌មានផ្សេងៗដើម្បីផ្តល់ជូន ។

-មន្ត្រីមានសមត្ថកិច្ច អាចចុះត្រួតពិនិត្យដោយពុំចាំបាច់ជូនដំណឹងជាមុនបានក្នុងគោលបំណងត្រួតពិនិត្យបន្ទាន់លើបញ្ហាកើតឡើងដោយការប្តឹងតវ៉ា ឬ ការរំលោភបំពានណាមួយ ។

-មុនពេលចុះធ្វើអធិការកិច្ចជាក់ស្តែង មន្ត្រីមានសមត្ថកិច្ចអាចធ្វើការពិនិត្យស្រាវជ្រាវឯកសារចាំបាច់នានាពាក់ព័ន្ធនឹងប្រភេទដំណើរការផលិតកម្ម លក្ខណៈផលិតផល ព័ត៌មានផ្សេងៗ អំពីហានិភ័យដែលអាចមាន និងប្រវត្តិនៃភាពអនុលោមរបស់រោងចក្រ-សិប្បកម្មពីមុន ដើម្បីរៀបចំមូលដ្ឋាន និងធ្វើផែនការចុះធ្វើអធិការកិច្ចរបស់ខ្លួនឱ្យបានច្បាស់លាស់ ។ មន្ត្រីមានសមត្ថកិច្ចត្រូវមានសម្ភារៈ បរិក្ខារប្រើប្រាស់ចាំបាច់សំរាប់ការងារអធិការកិច្ចផ្សេងៗ ដូចជាសំលៀកបំពាក់មានលក្ខណៈសមស្របសំរាប់គោលដៅដែលធ្វើអធិការកិច្ច និងឧបករណ៍ការពារផ្សេងៗ (បើចាំបាច់) និងបរិក្ខារទូទៅផ្សេងៗ ។ល។

-មន្ត្រីមានសមត្ថកិច្ច មិនត្រូវចុះធ្វើអធិការកិច្ចនៅពេលមានផ្ទុកជម្ងឺឆ្លងណាមួយ ដែលអាចបង្កឱ្យមានការចំលងរោគទៅដល់ផលិតផល ឬ ខ្សែសង្វាក់ផលិតកម្មដែលនឹងត្រូវត្រួតពិនិត្យ ។

-មន្ត្រីមានសមត្ថកិច្ច ត្រូវអនុវត្តតាមជំហានខាងក្រោមក្នុងការអនុវត្តការងារអធិការកិច្ចៈ

**ក. ក្នុងពេលដំណើរការចុះពិនិត្យរោងចក្រ-សិប្បកម្ម**

ក.១. កិច្ចប្រជុំចាប់ផ្តើមការងារ

នៅមុនពេលចូលទៅក្នុងទីតាំងរោងចក្រ-សិប្បកម្ម មន្ត្រីមានសមត្ថកិច្ចត្រូវមានឯកសណ្ឋានត្រឹមត្រូវ និង ណែនាំខ្លួនដល់ម្ចាស់រោងចក្រ-សិប្បកម្ម និងបង្ហាញលិខិតបេសកកម្ម និងប័ណ្ណសំគាល់ខ្លួន ។ មន្ត្រីមានសមត្ថកិច្ច ត្រូវពន្យល់អំពី គោលបំណង ក្របខ័ណ្ឌ វិសាលភាពនៃការធ្វើអធិការកិច្ច នីតិវិធី ដែលត្រូវអនុវត្តបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធផ្សេងៗ និងត្រូវពិនិត្យលើឯកសារ ទិន្នន័យដែលបានកត់ត្រា និងរក្សាទុកដោយរោងចក្រ-សិប្បកម្ម ព្រមទាំងពិនិត្យពិភាក្សាអំពីប្រព័ន្ធគ្រប់គ្រងគុណភាព និងសុវត្ថិភាព នៅក្នុងរោងចក្រ-សិប្បកម្ម ជាមួយម្ចាស់រោងចក្រ-សិប្បកម្ម ។

ក.២.ការពិនិត្យជាក់ស្តែង

មន្ត្រីមានសមត្ថកិច្ច ត្រូវប្រើប្រាស់បញ្ជីសំនួរដែលបានឯកភាពរៀបចំជាមុនជាមូលដ្ឋានក្នុងការត្រួតពិនិត្យជាក់ស្តែង លើដំណើរការប្រព្រឹត្តទៅនៃខ្សែសង្វាក់ ផលិតកម្មរបស់រោងចក្រ-សិប្បកម្ម ធ្វើការវាយតម្លៃពីភាពអនុលោមកំរិតហានិភ័យ និងប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងគុណភាពសុវត្ថិភាពផ្សេងៗរបស់រោងចក្រ-សិប្បកម្ម ។ មន្ត្រីមានសមត្ថកិច្ច ត្រូវធ្វើការសង្កេតរបៀបរបបធ្វើការ ធ្វើបទសំភាសន៍ជាមួយបុគ្គលិក-កម្មករ

ធ្វើការវាស់វែង និងធ្វើការយកសំណាកគំរូ សំរាប់ធ្វើវិភាគបន្ថែមតាមការចាំបាច់ ។ ក្នុងករណីចាំបាច់មន្ត្រីមានសមត្ថកិច្ច ត្រូវធ្វើការថតរូបបញ្ជាក់បន្ថែមដើម្បីបញ្ចូលក្នុងរបាយការណ៍ របស់ខ្លួន ។

ក.៣. កិច្ចប្រជុំបញ្ចប់

ក្រោយការបញ្ចប់ការត្រួតពិនិត្យជាក់ស្តែងលើខ្សែសង្វាក់ផលិតកម្មរបស់រោងចក្រ-សិប្បកម្ម មន្ត្រីមានសមត្ថកិច្ច និងម្ចាស់រោងចក្រ-សិប្បកម្មត្រូវធ្វើការប្រជុំបូកសរុបបញ្ចប់ការងារអធិការកិច្ចលើកនេះ ។ មន្ត្រីមានសមត្ថកិច្ចត្រូវពន្យល់ពីការរកឃើញរបស់ខ្លួនអំពីចំណុចដែលពុំមានភាពអនុលោម និងមានហានិភ័យពាក់ព័ន្ធដល់សុវត្ថិភាពផលិតផល ព្រមទាំងបទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធ នឹងចំណុចពុំមានភាពអនុលោមនេះ ។ ម្ចាស់រោងចក្រ-សិប្បកម្ម មានសិទ្ធិធ្វើការពន្យល់ពីហេតុផលដែលបណ្តាលឱ្យមានភាពមិនអនុលោម ហើយមន្ត្រីមានសមត្ថកិច្ចត្រូវព្យាយាមពន្យល់ និង ពិភាក្សាជាមួយម្ចាស់រោងចក្រ-សិប្បកម្ម លើដំណោះស្រាយចំពោះបញ្ហានេះ ។ មន្ត្រីមានសមត្ថកិច្ច និងម្ចាស់រោងចក្រ-សិប្បកម្ម អាចធ្វើការឯកភាពគ្នាលើផែនការសកម្មភាពមួយដែលមានកំណត់ពេលវេលាច្បាស់លាស់ ក្នុងការកែលំអចំណុចខ្វះខាត នានា ។ មន្ត្រីមានសមត្ថកិច្ចត្រូវរៀបចំកំណត់ហេតុ និងរបាយការណ៍អធិការកិច្ចដែលត្រូវចុះហត្ថលេខា ដោយមន្ត្រីមានសមត្ថកិច្ច និងម្ចាស់រោងចក្រ-សិប្បកម្ម ឬ អ្នកគ្រប់គ្រងជាតំណាង ហើយត្រូវថតចំលងមួយ ច្បាប់សំរាប់ផ្តល់ជូនម្ចាស់រោងចក្រ-សិប្បកម្ម ។

**ខ. ក្រោយការចុះពិនិត្យរោងចក្រ-សិប្បកម្ម**

មន្ត្រីមានសមត្ថកិច្ច ត្រូវរៀបចំរបាយការណ៍អធិការកិច្ច និងត្រូវរក្សាទុក ត្រឹមត្រូវក្នុងប្រព័ន្ធគ្រប់គ្រងឯកសារអធិការកិច្ចរោងចក្រ-សិប្បកម្ម សំរាប់ជាឯកសារយោងនាពេលក្រោយ ។ ក្នុងករណីមានភាពចាំបាច់ តម្រូវឱ្យធ្វើការតាមដានបន្តច្បាប់ថតចំលងនៃរបាយការណ៍ ត្រូវរក្សាទុកក្នុងប្រព័ន្ធឯកសារ ត្រូវតាមដានបន្តដោយឡែកមួយដែលរៀបចំតាមលំដាប់លំដោយនៃ កាលបរិច្ឆេទសំរាប់តាមដានបន្ត ។

ការត្រួតពិនិត្យតាមដានបន្ត អាចត្រូវបានអនុវត្តដោយការចុះអធិការកិច្ចម្តងទៀត ដោយពុំមានការជូនដំណឹងជាមុន ឬ ការចុះត្រួតពិនិត្យតែលើចំណុចដែលត្រូវធ្វើការកែលំអដើម្បីធានាថា រោងចក្រ-សិប្បកម្មបានអនុវត្តត្រឹមត្រូវតាមវិធានការ និងផែនការសកម្មភាពដែលបានដាក់ចេញ ឬ ព្រមព្រៀង ។

ម្ចាស់រោងចក្រ-សិប្បកម្ម ត្រូវទទួលបានការជូនដំណឹងអំពីលទ្ធផលនៃការធ្វើអធិការកិច្ច

និងការចាត់វិធានការចាំបាច់ផ្សេងៗតាមផ្លូវច្បាប់ចំពោះចំណុចខ្វះខាត និងភាពមិនអនុលោមនានាដែលបានរកឃើញស្របតាមការកំណត់ក្នុងប្រការទី១០ នៃប្រកាសនេះ។

## ប្រការ១០ ការចាត់វិធានការច្បាប់ដើម្បីពង្រឹងភាពអនុលោម

-ការចាត់វិធានការផ្សេងៗចំពោះរោងចក្រ-សិប្បកម្ម និងត្រូវកំណត់ផ្អែកតាមកំរិតនៃភាពមិនអនុលោមតាមការតម្រូវនៃច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ-សិប្បកម្ម និងស្តង់ដារបញ្ជា ស្តីពី គុណភាព និងសុវត្ថិភាព ដែលមានជាធរមាន និងដោយផ្អែកលើកំរិតហានិភ័យដល់សុខភាពសាធារណៈ។

-ផ្អែកលើលទ្ធផលនៃការងារធ្វើអធិការកិច្ច ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងករណីមានការផ្ទេរប្រតិភូកម្មអំណាចឱ្យអនុវត្តកិច្ចការនេះ និងចាត់វិធានការសមស្របតាមច្បាប់ ដើម្បីធានាឱ្យមានការពង្រឹងសុវត្ថិភាពផលិតផលដោយរោងចក្រ-សិប្បកម្ម ។

-វិធានការទាំងនោះអាចមានដូចតទៅ ៖

- ការផ្តល់ការក្រើនរំលឹក ឬ ជូនដំណឹងសំណូមពរឱ្យមានការកែលំអ ។
- ការចេញបញ្ជាជាផ្លូវការអំពីការតម្រូវឱ្យមានការកែលំអផ្សេងៗ ។
- ការហាមឃាត់ ឬផ្អាកសកម្មភាពរបស់រោងចក្រ-សិប្បកម្មជាបណ្តោះអាសន្ន។
- ការចេញលិខិតព្រមានជាផ្លូវការអំពីករណីមិនមានភាពអនុលោម ។
- ការអនុវត្តនីតិវិធីពិន័យអន្តរកាល និងរៀបចំបណ្តឹងទៅតុលាការស្របតាម ច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ។
- ការបញ្ឈប់ ឬ ឃាត់ទុកនូវផលិតផល សម្ភារៈវត្ថុធាតុដើម និងឯកសារ ពាក់ព័ន្ធនានាដែលអាចបណ្តាលឱ្យមានអន្តរាយដល់មនុស្ស ឬ ដល់ទ្រព្យសម្បត្តិក្នុងរោងចក្រ ឬ ទីជិតខាងរោងចក្រ ។
- វិធានការរួមគ្នាក្នុងចំណោមវិធានការទាំងអស់ខាងលើ ។

### ក. ការផ្តល់ការក្រើនរំលឹក ឬ ជូនដំណឹងសំណូមពរឱ្យមានការកែលំអ

ការផ្តល់ការក្រើនរំលឹក ឬ ជូនដំណឹងសំណូមពរឱ្យមានការកែលំអអាចត្រូវបានអនុវត្តដោយ មន្ត្រីមានសមត្ថកិច្ចតាមរយៈការផ្តល់អនុសាសន៍ណែនាំផ្ទាល់មាត់ដោយមន្ត្រីមានសមត្ថកិច្ច ឬ ការចេញលិខិតណែនាំផ្សេងៗ ដោយអគ្គនាយកដ្ឋានឧស្សាហកម្ម ឬ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រួមជាមួយការផ្តល់ច្បាប់ចំលងនៃរបាយការណ៍អធិការកិច្ច ឬ អាចត្រូវបានអនុវត្តភ្លាមៗបន្ទាប់ពីការធ្វើ

អធិការកិច្ចត្រូវបានបញ្ចប់ ។

អគ្គនាយកដ្ឋានឧស្សាហកម្ម និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល អាចប្រើប្រាស់វិធានការនេះ ដើម្បីណែនាំឱ្យមានភាពអនុលោមក្នុងករណីដែលយល់ឃើញថា ភាពមិនអនុលោមពុំមានកំរិតធ្ងន់ធ្ងរ និងមានទំនុកចិត្តច្បាស់ថា ម្ចាស់រោងចក្រ-សិប្បកម្ម នឹងអនុវត្តតាមសំណូមពរឱ្យមានការកែលំអប្រកបដោយប្រសិទ្ធភាពស្របតាមពេលវេលាដែលបានកំណត់ ហើយនិងធានាបាននូវការការពារដល់សុខភាព និងសុវត្ថិភាពសាធារណៈដោយពុំចាំបាច់ចេញបញ្ជាតម្រូវឱ្យកែលំអជាផ្លូវការ ។

ករណីខាងក្រោមអាចត្រូវបានយកមកពិនិត្យដើម្បីអនុវត្តវិធានការនេះ ៖

១-បញ្ហាពុំមានភាពធ្ងន់ធ្ងរ ដែលតម្រូវឱ្យមានការចាត់វិធានការជាផ្លូវការ ឬ ពុំមានហានិភ័យធ្ងន់ធ្ងរដល់ សុវត្ថិភាពអ្នកប្រើប្រាស់ ។

២-យោងតាមប្រវត្តិរបស់ម្ចាស់រោងចក្រ-សិប្បកម្ម គេអាចរំពឹងទុកចិត្តបានថា ការចេញវិធានការបែបនេះ នឹងត្រូវបានគោរពអនុវត្តតាមប្រកបដោយ ប្រសិទ្ធភាព និងអាចសំរេចបាននូវភាពអនុលោម ។

៣-ភាពមិនអនុលោម ពុំមានពាក់ព័ន្ធនឹងផលប្រយោជន៍សេដ្ឋកិច្ចណាមួយ របស់ម្ចាស់រោងចក្រ-សិប្បកម្ម ។

រាល់ការក្រើនរំលឹក ឬ ការជូនដំណឹងសំណូមពរឱ្យកែលំអផ្សេងៗ ត្រូវមានបញ្ជាក់ច្បាស់លាស់នូវព័ត៌មានអំពីបញ្ហា ដើម្បីជួយឱ្យម្ចាស់រោងចក្រ-សិប្បកម្ម យល់ច្បាស់ពីកាតព្វកិច្ច និងការងារដែលខ្លួនត្រូវអនុវត្តដើម្បីធ្វើការកែលំអ និង មូលហេតុចាំបាច់ដែលតម្រូវឱ្យធ្វើការកែលំអ ព្រមទាំងមានការបញ្ជាក់ច្បាស់លាស់ រវាងការតម្រូវដោយបទប្បញ្ញត្តិច្បាប់ ឬ ជាការអនុវត្តជាទំលាប់ទូទៅសំរាប់វិស័យ ឧស្សាហកម្ម ។

## ខ. ការចេញបញ្ជាជាផ្លូវការតម្រូវឱ្យមានការកែលំអ

លិខិតជូនដំណឹងផ្លូវការ បញ្ជាតម្រូវឱ្យធ្វើការកែលំអដើម្បីធានាភាពអនុលោម នឹងត្រូវចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងករណីមានប្រតិភូកម្មអំណាចចំពោះកិច្ចការនេះ ។ លិខិតនេះនឹង បញ្ជាក់ច្បាស់លាស់អំពី បញ្ហាមិនមានភាពអនុលោមដែលត្រូវធ្វើការកែតម្រូវដោយ ម្ចាស់រោងចក្រ-សិប្បកម្មជាដាច់ខាត និងពេលវេលាកំណត់ដើម្បីអនុវត្តឱ្យមាន ប្រសិទ្ធភាព ។ ការខកខានមិនបានអនុវត្តពេញលេញតាមបញ្ញត្តិក្នុងលិខិតនេះ

នឹងត្រូវចាត់ទុកថាជាអំពើល្មើសនឹងច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ការចេញលិខិតបញ្ជាផ្លូវការតម្រូវឱ្យធ្វើការកែតម្រូវ នឹងត្រូវអនុវត្តនៅពេលការពិនិត្យវាយតម្លៃបានបញ្ជាក់ថាបញ្ហា ភាពមិនអនុលោមមានកំរិតធ្ងន់ធ្ងរបានកើតមានឡើងនៅក្នុងរោងចក្រ-សិប្បកម្ម ហើយបញ្ហានេះនឹងបន្តកើតមានឡើងជាបន្តបន្ទាប់ទៀត ប្រសិនបើពុំមានការចាត់វិធានការតឹងរ៉ឹងតាមផ្លូវច្បាប់ទេនោះ ។

ករណីខាងក្រោមអាចត្រូវបានយកមកពិនិត្យដើម្បីអនុវត្តវិធានការនេះ ៖

១-មានការប្រព្រឹត្ត ឬ រោងចក្រ-សិប្បកម្មត្រូវបានដំណើរការខុសពីបទដ្ឋានបច្ចេកទេសកំណត់ដោយក្រសួង ឬ បទប្បញ្ញត្តិនៃច្បាប់ធ្ងន់ធ្ងរ ។

២-ការចាត់វិធានការផ្លូវច្បាប់គឺជាភាពចាំបាច់ ដើម្បីធានាទប់ស្កាត់ហានិភ័យដល់សុខភាព និងសុវត្ថិភាពសាធារណៈ ។

៣-ការពុំមានទំនុកចិត្តថា ម្ចាស់រោងចក្រ-សិប្បកម្មនឹងអនុវត្តការកែតម្រូវនៅពេលមានសំណូមពរឱ្យអនុវត្ត ឬ ការក្រើនរំលឹក ។

៤-ធ្លាប់មានប្រវត្តិ មិនអនុលោមកន្លងមកទោះជាមានការក្រើនរំលឹក ឬសំណូមពរឱ្យមានការកែតម្រូវក៏ដោយ ។

៥-ហានិភ័យដែលអាចបង្កឡើង ក្នុងករណីដែលម្ចាស់រោងចក្រ-សិប្បកម្មពុំព្រមអនុវត្តការកែតម្រូវមានសភាព ធ្ងន់ធ្ងរអាចប៉ះពាល់ដល់សុខភាព និងសុវត្ថិភាពសាធារណៈ ។

៦-ម្ចាស់រោងចក្រ-សិប្បកម្ម បានបង្ហាញឱ្យឃើញនូវភាពមិនចង់ទទួលស្គាល់ការទទួលខុសត្រូវរបស់ខ្លួន ចំពោះហានិភ័យ និងផលប៉ះពាល់ផ្សេងៗ ។

៧-ភាពមិនអនុលោម មានពាក់ព័ន្ធនឹងផលប្រយោជន៍សេដ្ឋកិច្ចណាមួយ របស់ម្ចាស់រោងចក្រ-សិប្បកម្ម ។

៨-វិធានការត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពជាបន្ទាន់ ដើម្បីដោះស្រាយបញ្ហាធ្ងន់ធ្ងរដែលអាចមានមហន្តរាយចំពោះមុខ ។

មន្ត្រីមានសមត្ថកិច្ច ត្រូវប្រជុំពិភាក្សាជាមួយម្ចាស់រោងចក្រ-សិប្បកម្ម តាមការចាំបាច់ជាក់ស្តែងដើម្បីពន្យល់ពីការចាត់វិធានការជាផ្លូវការ និងដោះស្រាយចំណុចខ្វែងមតិគ្នា តាមលទ្ធភាពដែលអាចធ្វើទៅបាននៅមុនពេលចេញលិខិតផ្លូវការ បញ្ជាតម្រូវឱ្យធ្វើការកែលំអ ។

**គ. ការផ្អាកដំណើរការ ឬ បញ្ឈប់សកម្មភាពរបស់រោងចក្រ-សិប្បកម្មជាបណ្ដោះអាសន្ន**

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នឹងចេញសេចក្ដីសំរេចផ្អាកដំណើរការ ឬ បញ្ឈប់សកម្មភាពរបស់រោងចក្រ-សិប្បកម្មទាំងស្រុងជាបន្ទាន់នៅពេលពិនិត្យឃើញបទល្មើសជាក់ស្ដែងដែលមានហានិភ័យធ្ងន់ធ្ងរ ឬ បានបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាពសាធារណៈ ។ ការចេញសេចក្ដីសំរេចផ្អាក ឬ បញ្ឈប់ដំណើរការរោងចក្រ-សិប្បកម្ម និងត្រូវអនុវត្តក្នុងករណីណាមួយខាងក្រោមកើតមានឡើង ហើយពុំមានសញ្ញាណាមួយបញ្ជាក់ថា ម្ចាស់រោងចក្រ-សិប្បកម្មស្ម័គ្រចិត្តបញ្ឈប់ជាបន្ទាន់នូវសកម្មភាព ឬ ស្ថានភាពបទល្មើសទាំងនេះមិនឱ្យមានតទៅទៀតទេ:

១-រោងចក្រ-សិប្បកម្ម ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរនឹងច្បាប់ជាធរមាន ។

២-រោងចក្រ-សិប្បកម្ម បានបង្កឱ្យមានការចំលងមេរោគ ការបំពុល ឬ គ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាពសាធារណៈ ឬ កំពុងបង្កើតឡើងនូវហានិភ័យទាំងអស់នេះ ។

៣-ចំពោះករណីឧស្សាហកម្មម្ហូបអាហារ ត្រូវបានរកឃើញភស្ដុតាងពីវត្តមានសត្វចង្រៃ កណ្ដុរ កន្លាតឬ សត្វល្អិត ចង្រៃផ្សេងៗទៀតជាច្រើនដែលអាចបង្ក ហានិភ័យធ្ងន់ធ្ងរ ក្នុងការចំលងមេរោគ ឬ បំពុល ដល់ផលិតផលម្ហូបអាហារ ឬ មានស្ថានភាពខ្វះអនាម័យធ្ងន់ធ្ងរគ្មានការលាងសំអាត ឬ ប្រកាន់គោលការណ៍អនាម័យត្រឹមត្រូវ គ្មានការគ្រប់គ្រងសំរាម និងសំណល់ផ្សេងៗត្រឹមត្រូវដែលបង្ក ឱ្យមានហានិភ័យខ្ពស់ដល់គុណភាព និងសុវត្ថិភាពផលិតផលម្ហូបអាហារ ។

៤-ក្នុងករណីសេចក្ដីសំរេច ផ្អាកដំណើរការឬបញ្ឈប់សកម្មភាពរបស់រោងចក្រ-សិប្បកម្ម មានការពាក់ព័ន្ធ នឹងការបំពុលដោយសារធាតុគីមី ឬ ហានិភ័យបណ្ដាលមកពីបញ្ហាបច្ចេកទេសផ្សេងៗ ក្រសួងអាចតម្រូវឱ្យមានការផ្ដល់ប្រឹក្សាយោបល់បច្ចេកទេសជាមួយជំនាញបច្ចេកទេសពាក់ព័ន្ធជាមុន មុននឹងចេញ សេចក្ដីសំរេចនេះ ។

ម្ចាស់រោងចក្រ-សិប្បកម្មត្រូវធ្វើការផ្អាក ឬ បញ្ឈប់ដំណើរការរោងចក្រ-សិប្បកម្មជាបន្ទាន់តាមកំណត់ការនៃ លិខិតជូនដំណឹងរបស់ក្រសួងស្ដីពីសេចក្ដីសំរេចផ្អាក ឬ បញ្ឈប់សកម្មភាពរបស់រោងចក្រ-សិប្បកម្ម ។ ក្នុងករណីមានការជំទាស់និងសេចក្ដីសំរេចនេះ ម្ចាស់រោងចក្រ-សិប្បកម្ម អាចធ្វើលិខិតតវ៉ាទាស់ជាផ្លូវការ

មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេល ០៧ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយទទួលបានលិខិតជូនដំណឹងឱ្យផ្អាក ឬបញ្ឈប់ ។ ក្នុងករណីមូលហេតុនៃការជំទាស់នេះ ពុំត្រូវបានទទួលយកដោយក្រសួង ម្ចាស់រោងចក្រ-សិប្បកម្ម មានសិទ្ធិធ្វើបណ្តឹងទៅតុលាការ ឬ មជ្ឈត្តវិនិច្ឆ័យពាណិជ្ជកម្មដើម្បីដោះស្រាយការជំទាស់តវ៉ារបស់ខ្លួន ។

## ឃ. ការផ្អាកឬបញ្ឈប់រោងចក្រ-សិប្បកម្មដោយស្ម័គ្រចិត្ត

ក្នុងករណីម្ចាស់រោងចក្រ-សិប្បកម្មស្ម័គ្រចិត្តធ្វើការផ្អាក ឬ បញ្ឈប់ដោយខ្លួនឯងរហូតដល់បញ្ហាហានិភ័យត្រូវបានដោះស្រាយ ឬ លែងមានហានិភ័យប៉ះពាល់សុវត្ថិភាព និងសុខុមាលភាពសាធារណៈ សំណើសុំផ្អាក ឬ បញ្ឈប់សកម្មភាពរោងចក្រ-សិប្បកម្មដោយស្ម័គ្រចិត្ត អាចធ្វើទៅបានក្នុងករណីដូចខាងក្រោម ៖

១-មន្ត្រីមានសមត្ថកិច្ចមានទំនុកចិត្តថាម្ចាស់រោងចក្រ-សិប្បកម្មពុំមានចេតនា ឬ លួចបន្តសកម្មភាពរបស់ រោងចក្រ-សិប្បកម្ម បន្ទាប់ពីការផ្អាក ឬ បញ្ឈប់ដោយពុំមានការអនុញ្ញាតឱ្យដំណើរការឡើងវិញ ពីក្រសួងឡើយ ។

២-សំណើសុំផ្អាក ឬ បញ្ឈប់ត្រូវបានចុះហត្ថលេខាបញ្ជាក់ត្រឹមត្រូវដោយ ម្ចាស់រោងចក្រ-សិប្បកម្ម និងត្រូវបានទទួលការឯកភាពពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

## ង. ការចេញលិខិតព្រមានផ្លូវការអំពីភាពមិនអនុលោម

យោងតាមភាពចាំបាច់តាមស្ថានភាពនីមួយៗ និងឆន្ទានុសិទ្ធិរបស់ក្រសួងក្នុងករណីខ្លះ ដែលក្រសួងយល់ថា ពុំទាន់មានការចាំបាច់ត្រូវធ្វើការពិន័យអន្តរកាល ឬ ការបញ្ជូនសំណុំរឿងប្តឹងទៅតុលាការ ក្រសួងអាចសំរេចធ្វើការព្រមានផ្លូវការដល់រោងចក្រ-សិប្បកម្ម ចំពោះភាពមិនអនុលោមរបស់ខ្លួនជាបឋមសិនជំនួសឱ្យការពិន័យ ឬ ការប្តឹងទៅតុលាការ ។

ករណីដូចខាងក្រោមអាចត្រូវបានយកមកពិនិត្យក្នុងការចេញលិខិតព្រមានផ្លូវការ ៖

១-កំហុសនៃភាពមិនអនុលោមមានលក្ខណៈតូចតាច ហើយជាលើកទី១ ដែលកើតមាន ។

២-កំហុសនៃភាពមិនអនុលោមមានលក្ខណៈធ្ងន់ធ្ងរ ប៉ុន្តែម្ចាស់រោចក្រ-សិប្បកម្ម បានខិតខំដោះស្រាយបញ្ហារួចរាល់យ៉ាងឆាប់រហ័ស និងបានចាត់វិធានការគ្រប់គ្រាន់ការពារមិនឱ្យសភាពការណ៍នេះកើតឡើង ម្តងទៀត ។

៣-រោងចក្រ-សិប្បកម្ម ត្រូវបានផ្អាក ឬ បញ្ឈប់សកម្មភាពចាប់តាំងពីពេលដែល

បញ្ហាបានកើតឡើង មកម្ល៉េះ ។

**ច. ការអនុវត្តនីតិវិធីពិន័យអន្តរកាល និងរៀបចំបណ្តឹងទៅតុលាការ**

ការខកខានពុំគោរពតាម ឬ អនុវត្តតាមទាំងស្រុងប្រកបដោយប្រសិទ្ធភាព នូវបទបញ្ជា ឬ សេចក្តីតម្រូវផ្លូវការផ្សេងៗរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវចាត់ទុកថាជាបទល្មើសនឹងច្បាប់ ស្តីពី ការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម លើកលែងតែករណីដូចខាងក្រោមៈ

១- ខ្លឹមសារ និងបញ្ហាចំបងៗនៃការតម្រូវក្នុងសេចក្តីជូនដំណឹង ត្រូវបានកែតម្រូវឱ្យមានភាពអនុលោមរួចហើយ ប៉ុន្តែបញ្ហានៅសល់មានលក្ខណៈបន្ទាប់បន្សំ និងពុំមានហានិភ័យធ្ងន់ធ្ងរដល់សុខភាព និង សុវត្ថិភាពសាធារណៈ ។

២- កិច្ចការដែលត្រូវធ្វើបានចាប់ផ្តើមរួចហើយ (តាមរយៈភស្តុតាង ឬ អំណះអំណាងច្បាស់លាស់បញ្ជាក់ ពីការបានចាប់ផ្តើមរួចហើយ) ហើយក្រសួងបានផ្តល់គោលការណ៍ឯកភាពពន្យារពេលដល់ ម្ចាស់រោងចក្រ-សិប្បកម្ម ដើម្បីបញ្ចប់កិច្ចការនេះទាំងស្រុងតាមសំណើសុំរបស់ ម្ចាស់រោងចក្រ-សិប្បកម្ម ។

ការចាត់វិធានការលើបទល្មើស និងនីតិវិធីពិន័យអន្តរកាល នឹងត្រូវអនុវត្តស្របតាមច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ក្នុងជំពូកស្តីពីទោសប្បញ្ញត្តិ និងច្បាប់ផ្សេងៗទៀតដែលមានជាធរមានពាក់ព័ន្ធនឹងហានិភ័យ ឬផលប៉ះពាល់ដែលបង្កឡើងជាក់ស្តែងដោយរោងចក្រ-សិប្បកម្ម ។

**ឆ. ការបញ្ឈប់ ឬ ឃាត់ទុកនូវផលិតផល សម្ភារៈវត្ថុធាតុដើម និងឯកសារពាក់ព័ន្ធនានា ដែលអាចបណ្តាលឱ្យមានអន្តរាយដល់មនុស្ស ឬ ដល់ទ្រព្យសម្បត្តិក្នុងរោងចក្រ ឬ នៅជិតខាង រោងចក្រ**

ក្នុងករណីមានភ័ស្តុតាង និងអំណះអំណាងច្បាស់លាស់បញ្ជាក់ពីហានិភ័យដល់សុខភាព និងសុវត្ថិភាពសាធារណៈបណ្តាលមកពីផលិតផលដែលបានផលិតរួចហើយ ឬ ដំណើរការផលិតកម្មរបស់រោងចក្រ-សិប្បកម្ម មន្ត្រីមានសមត្ថកិច្ចអាចតម្រូវឱ្យផ្អាកការបញ្ចេញចរាចរផលិតផលរោងចក្រ-សិប្បកម្មជាបន្ទាន់ ឬ ឃាត់ទុកសម្ភារៈវត្ថុធាតុដើម ក្នុងរយៈពេលបណ្តោះអាសន្នមួយ ដើម្បីចាត់វិធានការចាំបាច់

ផ្សេងៗទៀតជាបន្ត ។ មន្ត្រីមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុកត់ត្រាបរិមាណ ផលិតផល ឬ សម្ភារៈវត្ថុធាតុដើមដែលមានបញ្ហាដោយមានបញ្ជីរាយមុខផលិតផល និង អត្តសញ្ញាណលំអិតរបស់ផលិតផលនីមួយៗច្បាស់លាស់ដោយមានការចុះហត្ថលេខាទទួលស្គាល់ និងឯកភាពដោយម្ចាស់ រោងចក្រ-សិប្បកម្ម ។

ការតម្រូវឱ្យផ្អាកចរាចរផលិតផល ឬ ការឃាត់ទុកសម្ភារៈវត្ថុធាតុដើម ត្រូវធ្វើឡើងក្នុងគោលបំណងដើម្បី ការពារកុំឱ្យមានការប្រើប្រាស់ផលិតផល ឬ សម្ភារៈវត្ថុធាតុដើមដែលមានហានិភ័យ ។ ក្នុងករណីចាំបាច់មន្ត្រីមានសមត្ថកិច្ចត្រូវធ្វើសំណើមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីសុំអន្តរាគមន៍ទៅតុលាការ និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធ្វើការរឹបអូសយក ឬ ប្រមូលបង្ខាំងទុក ឬ បំផ្លាញចោលផលិតផលទាំងអស់ដែល មានហានិភ័យ ។

**ប្រការ១១** **អវសានប្បញ្ញត្តិ**

-អគ្គនាយកដ្ឋានឧស្សាហកម្ម វិទ្យាស្ថាន នាយកដ្ឋាន អង្គភាពចំណុះអគ្គនាយកដ្ឋានឧស្សាហកម្ម អង្គភាពចំណុះអគ្គនាយកដ្ឋានក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត រោងចក្រ-សិប្បកម្មទាំងអស់ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ស៊ុយ_សែម

**ចម្លងជូន:**

-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**នាយករដ្ឋមន្ត្រី
-ទីស្តីការ គណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួង មហាផ្ទៃ
-ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួង សុខាភិបាល
-ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
-ក្រសួង ព័ត៌មាន
-ក្រសួង យុត្តិធម៌
-គ្រប់សាលា រាជធានី-ខេត្ត
-គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត" ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ